**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ**

**THE STUDENT MOVEMENT FOR DEMOCRACY**

លេខ៖ ០០១៧/២០ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០

# សេចក្តីថ្លែងការណ៍
## ថ្កោលទោសរដ្ឋាភិបាលភ្នំពេញ
## ករណីចាប់ឃាត់ខ្លួនយុវជន/យុវតី៦រូប

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមថ្កោលទោសអាជ្ញាធររដ្ឋាភិបាល ដែលបានចាប់ឃាត់ខ្លួនយុវជន និងយុវតី សរុប៦នាក់ នៅភ្នំពេញ ដោយសកម្មភាពហឹង្សា និងការរំលោភបំពានយ៉ាងអមនុស្សធម៌ ស្របពេលដែលយុវជន និងយុវតីខ្មែរទាំង៦រូប គ្រាន់តែប្រើសិទ្ធិស្របរដ្ឋធម្មនុញ្ញរបស់ពួកគាត់ ក្នុងការតវ៉ាទាមទារយុត្តិធម៌ ជូនលោក **រ៉ុង ឈុន** នៅថ្ងៃទី១៣ ខែសីហានេះ ។

ប្រតិបត្តិការទាំងកម្រោល នៃកម្លាំងសមត្ថកិច្ចភ្នំពេញ គឺជាចេតនាបែបផែនការយុទ្ធសាស្រ្តនយោបាយអសុចរិតក្នុងការបន្តសង្កត់សង្កិនយ៉ាងដំណំ លើសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ដែលធានាដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។

- មាត្រា៣៥ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា *«ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។ សេចក្តីស្នើទាំងឡាយ របស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ»* ។
- ត្រង់មាត្រា៤១ កថាខណ្ឌទី១ នៃរដ្ឋធម្មន្ទញ្ញកម្ពុជា ចែងថា *«ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ»* ។
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១៩ ចែងថា *«មនុស្សគ្រប់រូប មានសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិ និងការសម្តែងមតិ ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការបញ្ចេញមតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាព ក្នុងការស្វែងរកការទទួលនិងការផ្សព្វផ្សាយព័តមាន និងគំនិតនានា ដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ»* ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ទាមទារអាជ្ញាធររដ្ឋាភិបាលភ្នំពេញ ផ្តល់សេរីភាពពេញលេញដល់យុវជននិងយុវតីទាំង៦រូប ឲ្យអាចបន្តសកម្មភាពស្របច្បាប់របស់ពួកគាត់ឡើងវិញ ។

**ជ.គណៈកម្មាធិការប្រតិបត្តិ**

**អនុប្រធាន**

Séng

**អ៊ាប សេង**